**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**
**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
លេខ: ០៣២ ស្ទួន សហអ

**<u>សូមគោរពជូន</u>**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

<u>តាមរយៈ</u> ឯកឧត្តមអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ

<u>កម្មវត្ថុ:</u> របាយការណ៍ស្តីពីកិច្ចប្រជុំគណៈកម្មការអនុវត្តន៍ (IC) លើកទី១៦

<u>ភ្ជាប់ជូន:</u> របៀបវារៈនៃកិច្ចប្រជុំ និងបញ្ជីវត្តមាន

ឆ្នាំពីរពាន់ដប់ពីរ ខែ កុម្ភៈ ថ្ងៃទី ប្រាំមួយ នៅក្រសួងពាណិជ្ជកម្មបានបើកកិច្ចប្រជុំនៃគណៈកម្មការអនុវត្តន៍ (IC) លើកទី១៦ ក្រោមអធិបតីភាព ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអនុវត្តន៍ (IC) ដោយមានសមាជិក សមាជិកា នៃគណៈកម្មាការមកពីក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធចូលរួមពិភាក្សាលើរបៀបវារៈដូចដែលបានគ្រោងទុក ។

របៀបវារៈកិច្ចប្រជុំ និងចំណុចសំខាន់ៗដែលបានពិភាក្សារួមមាន:

- របាយការណ៍វឌ្ឍនភាពរបស់គម្រោង TDSP
- ធ្វើបច្ចុប្បន្នភាពអំពីផែនទីបង្ហាញផ្លូវសេរសេរស្តម្ភ
- ធ្វើបច្ចុប្បន្នភាពអំពីដំណើរការនៃការអនុម័តគម្រោង TDSP និងការបង្កើត EIF Tier 2

បន្ទាប់ពីលោក ឈៀង ពេជ្រ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានរាយការណ៍ជូនកិច្ចប្រជុំអំពីវឌ្ឍនភាពរបស់គម្រោង TDSP ដែលបានបង្ហាញនូវពង្រៀងនៃការដាក់កំណត់ថ្មី (Benchmarks) ដោយធនាគារពិភពលោកក្នុងការអនុវត្តគម្រោង TDSP បន្តរយៈពេលពីរឆ្នាំទៀតដែលរួមមានចំនួន២៦ចំណុច (ដូចមានភ្ជាប់នៅក្នុង Presentation Slide) និងការៀបចំផែនការការងារ និងផែនការថវិកាឆ្នាំ ២០១២ របស់គម្រោង TDSP ព្រមទាំងបោយការណ៍វឌ្ឍនភាពរបស់ Pillars ស្តីអំពី បច្ចុប្បន្នភាពអំពីផែនទីបង្ហាញផ្លូវសេរសេរស្តម្ភ ដែលបានរាយការណ៍ជូនអង្គប្រជុំដោយតំណាង ក្រុមការងារសេរសេរស្តម្ភទាំងបី និងពិភាក្សាយ៉ាងលំអិតលើ TDSP Project Approval Process រួចមក ជូសមុខគណៈកម្មាការអនុវត្តន៍គម្រោង (IC) ឯកឧត្តម ប៉ាន សូរស័ក្តិ បានធ្វើការបូកសរុបជាលទ្ធផលរួមដូចខាងក្រោម:

- សម្រេចបំពេញបន្ថែមនូវតំណែងដែលនៅចន្លោះចំនួន ០២ តំណែង គឺតំណែងអ្នកចាត់ចែងគម្រោងថ្នាក់ជាតិ និងរដ្ឋបាល ។
- អនុស្សរណៈនៃការយោគយល់គ្នា (MOUs) ដែលផុតកំណត់ ត្រូវអញ្ជើញ (IAs) ដែលជាម្ចាស់គម្រោងមកធ្វើ (MOUs) សារជាថ្មី ។
- ការកែទម្រង់លើដំណើរការនៃការអនុម័តគម្រោង TDSP នឹងត្រូវរៀបចំសារជាថ្មី ដោយយោងតាមស្មារតីសេចក្តីសម្រេចលេខ ៧៦ សសរ ដែលមាននាយកដ្ឋាន DICO ជាលេខាធិការដ្ឋាន ។

- ឯកភាព និងទទួលស្គាល់ចំពោះផែនទីបង្ហាញផ្លូវចុងក្រោយ របស់ក្រុមការងារសរសេរស្គម្ភទី ១ និង ទី ២ ។
- ទទួលស្គាល់អំពីវឌ្ឍនភាពរបស់ក្រុមការងារសរសេរស្គម្ភទី ៣ ដែលត្រូវការពេលវេលាបន្ថែម ដើម្បីធ្វើបច្ចុប្បន្នភាពសូចនាករទាំងអស់ឡើងវិញ ។
- អញ្ជើញតំណាងធនាគារពិភពលោកប្រជុំជាលក្ខណៈ ADHOC ដើម្បីធ្វើកំណត់ហេតុ (Minute) ទុកជាឯកសារ ។
- សូមឲ្យធ្វើការជាមួយនាយកដ្ឋាន DICO ដើម្បីពិនិត្យ MOU និងធ្វើការកែប្រែ (Revise) ថវិកាឡើងវិញចំពោះសំណូមពររបស់តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសុំប្តូរពីគម្រោងទស្សនៈកិច្ចសិក្សា មកធ្វើការបោះពុម្ពវិញ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១២:០០ក្នុងបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលល្អ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម មេត្តាជ្រាបជារបាយការណ៍ និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

ហាង សុជីវិន

លេខាធិការ

ចម្លងជូន:

ឯ.ឧ ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការអនុវត្តគម្រោង

ឯ.ឧ លោក លោកស្រី ប្រធានក្រុមការងារសរសេរស្គម្ភទី១ ទី២ និងទី៣

គោរពជូន **ឯ.ឧរដ្ឋលេខាធិការ**

ដើម្បីសុំការឯកភាពគោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រាប

13/02/2012

**សុខ សុផាត្រា**

សមាជិកអចិន្ត្រៃយ៍ គណៈកម្មាការអនុវត្តគម្រោង

បានឃើញ និង ឯកភាព

គោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**

**ប៉ាន សូរស័ក្តិ**

ប្រធានគណៈកម្មាការអនុវត្តគម្រោង

# TDSP Project Approval Process

